ព័ត៌មានទូទៅអំពីគម្រោង

# AIR-C3: គម្រោងបែបស្រាវជ្រាវ និងអនុវត្តន៍សម្រាប់ការលើកកម្ពស់ការចម្អិនអាហារស្អាត តាមរយៈ ការប្រើប្រាស់ចង្ក្រានអគ្គិសនីនៅកម្ពុជា

## ទិដ្ឋភាពទូទៅ

- **ហេតុអ្វីផ្តោតលើការចម្អិនអាហារស្អាត?** មនុស្សប្រមាណ ៣ ពាន់លាននាក់នៅទូទាំងពិភពលោក នៅតែចម្អិនអាហារដោយប្រើអុស និងធ្យូង។ ផ្សែងដែលចេញពីការដុតឥន្ធនៈជីវម៉ាសទាំងនេះ ធ្វើឱ្យខ្យល់ក្នុងផ្ទះកខ្វក់ ហើយជាមូលហេតុមួយបណ្តាលឱ្យមនុស្សរាប់លាននាក់ស្លាប់មុនអាយុជារៀងរាល់ឆ្នាំ។ ផ្សែងនេះក៏អាចជាកត្តាដែលបង្កឱ្យមានជំងឺបេះដូង ជំងឺផ្លូវដង្ហើម ជំងឺទឹកនោមផ្អែម និងជំងឺមហារីកផងដែរ។
- **តើ AIR-C3 ជាអ្វី?** AIR-C3 ជាគម្រោងសិក្សាបែបស្រាវជ្រាវ និងអនុវត្តន៍សម្រាប់ការចម្អិនអាហារស្អាតនៅកម្ពុជា អនុវត្តក្នុងរយៈពេល ៥ ឆ្នាំ (២០២៥–២០២៩) ដើម្បីស្វែងយល់អំពីរបៀប ឬវិធីសាស្ត្រដែលនាំឱ្យ ប្រជាជនកម្ពុជាអាចប្តូរមកប្រើចង្ក្រានអាំងឌុចស្យុង (ចង្ក្រានអគ្គិសនី) ហើយតើការចម្អិនជាមួយចង្ក្រានអគ្គិសនី អាចជួយកាត់បន្ថយការបំពុលខ្យល់ក្នុងផ្ទះ ជាជាងការចម្អិនអាហារដោយប្រើឥន្ធនៈជីវម៉ាសដែរឬទេ។
- **តើនរណាខ្លះចូលរួមអនុវត្តគម្រោងនេះ?** គម្រោងនេះជាកិច្ចសហការរវាងអ្នកស្រាវជ្រាវមកពីសាកលវិទ្យាល័យអាមេរិកចំនួន ៤ ដូចជា សាកលវិទ្យាល័យ Emory - សាកលវិទ្យាល័យ California, Berkeley School of Public Health - សាកលវិទ្យាល័យ South Carolina និង Colorado State University ដោយមាន អង្គការ iDE កម្ពុជា ជាអ្នកដឹកនាំការអនុវត្តគម្រោងផ្ទាល់។ គម្រោងសិក្សានេះ ទទួលបានការឧបត្ថម្ភមូលនិធិពីវិទ្យាស្ថានជាតិសុខាភិបាលនៃសហរដ្ឋអាមេរិក (NIH)។



## ហេតុអ្វីការចម្អិនអាហារស្អាតមានសារៈសំខាន់នៅកម្ពុជា

ជាក់ស្តែងក្នុងប្រទេសកម្ពុជា ប្រជាជនប្រមាណ ៦០% នៅតែបន្តពឹងផ្អែកលើការចម្អិនដោយប្រើអុស ឬធ្យូងជាប្រចាំថ្ងៃសម្រាប់តម្រូវការចម្អិនមួយចំនួន ឬទាំងស្រុងតែម្តង។ ផ្សែងពុលកើតចេញពីការដុតអុស ឬធ្យូងនេះ បានរួមចំណែកធ្វើឱ្យមនុស្សប្រមាណ **១៨,៤០០ នាក់** ស្លាប់នៅកម្ពុជា ក្នុងឆ្នាំ ២០២១។

លើសពីផលប៉ះពាល់សុខភាព ការចម្អិនអាហារដោយឥន្ធនៈជីវម៉ាស ក៏អាចបង្កើតបន្ទុកសេដ្ឋកិច្ច បរិស្ថាន និងពេលវេលាផងដែរ រួមមាន ថ្លៃចំណាយទិញអុស ឬធ្យូង ប៉ះពាល់ដល់ធនធានព្រៃឈើ និងបរិស្ថាន ឬពេលវេលាដែលត្រូវចំណាយក្នុងការប្រមូលអុសជាដើម។ ប៉ុន្តែជាឱកាសល្អ ដោយឃើញថាឥឡូវនេះស្ទើរតែគ្រប់ខ្នងផ្ទះនៅក្នុងប្រទេសកម្ពុជាមានអគ្គិសនីប្រើប្រាស់រួចហើយ។ ដូច្នេះ ការងាកមកចាប់អារម្មណ៍លើការប្រើប្រាស់**ចង្ក្រានអគ្គិសនី**អាចក្លាយជាជម្រើសដំណោះស្រាយដ៏ល្អមួយក្នុងការជំរុញការចម្អិនអាហារស្អាត និងងាយស្រួល។



## សកម្មភាពរបស់គម្រោង AIR-C3

គម្រោងនេះ កំពុងសិក្សាវាយតម្លៃទៅលើវិធីសាស្ត្រណាខ្លះ ដែលអាចជំរុញអោយមានការទទួលយក និងលើកកម្ពស់ការប្រើប្រាស់ចង្ក្រានអគ្គិសនី នៅក្នុងភូមិគោលដៅចំនួន ៦៥ ភូមិ ស្ថិតនៅក្នុងស្រុកចំនួន ៥ មានដូចជា៖ ស្រុកសំរោងទង ស្រុកច្បារមន និងស្រុកគងពិសី ក្នុងខេត្តកំពង់ស្ពឺ ព្រមទាំងស្រុកស្អាង និងស្រុកកណ្តាលស្ទឹង ក្នុងខេត្តកណ្តាល។ ការសិក្សានេះរួមបញ្ចូលគ្នានូវសកម្មភាពអនុវត្តតាមសហគមន៍ ការស្ទង់មតិគ្រួសារ ការសម្ភាសន៍ ការតាមដានការប្រើប្រាស់ចង្ក្រានបន្ទាប់ពីទិញរួច និងការវាស់វែងកម្រិតនៃផលប៉ះពាល់ផ្សែង ឬខ្យល់ពុលក្នុងផ្ទះ។

**តាមរយៈសកម្មភាពទាំងនេះ គម្រោង AIR-C3 មានគោលដៅស្វែងយល់អំពី៖**

- វិធីសាស្ត្រដែលមានប្រសិទ្ធភាពបំផុតក្នុងការលើកទឹកចិត្តគ្រួសារនីមួយៗឱ្យទិញ និងប្រើប្រាស់ចង្ក្រានអគ្គិសនីជាប្រចាំ។
- តើវិធីសាស្ត្រទាំងនេះជួយកាត់បន្ថយការប្រើប្រាស់ឥន្ធនៈជីវម៉ាសសម្រាប់ការចម្អិនអាហារដែរឬទេ។
- តើវិធីសាស្ត្រទាំងនេះដំណើរការយ៉ាងដូចម្តេចចំពោះស្ថានភាពគ្រួសារផ្សេងៗគ្នា រួមទាំងអ្នកមានចំណូលទាប។
- ការចំណាយ អត្ថប្រយោជន៍ និងមេរៀនដែលរៀនសូត្របានពីវិធីសាស្ត្រនីមួយៗ។

### ការប្រើប្រាស់ប្រភេទចង្ក្រាន




### ការប្រើប្រាស់អគ្គសនីក្នុងមួយថ្ងៃ




## ការយល់ដឹងសំខាន់ៗ មុនពេលរៀបចំគម្រោង

មុនពេលរៀបចំសកម្មភាពដែលត្រូវអនុវត្ត យើងបានរៀបចំការស្ទង់មតិ និងការចុះសម្ភាសន៍ជាមួយគ្រួសារ ក៏ដូចជាភាគីពាក់ព័ន្ធក្នុងសហគមន៍ផ្ទាល់ ដើម្បីស្វែងយល់កាន់តែច្បាស់ពីរបៀបចម្អិនអាហារ និងកត្តាដែលអាចជះឥទ្ធិពលដល់ការទិញ និងការប្រើប្រាស់ចង្ក្រានអគ្គិសនី ក៏ដូចជាការបន្តប្រើប្រាស់ចង្ក្រានប្រើឥន្ធនៈជីវម៉ាសផងដែរ។

ការងារនេះរួមមានការសម្ភាសន៍ជាមួយអ្នកចូលរួមជាង ១០០នាក់ និងការសិក្សាពីចំណាប់អារម្មណ៍ឆន្ទៈចង់ទិញ ជាមួយគ្រួសារចំនួន ២៥០ នៅក្នុងស្រុកគោលដៅទាំង ៥ ដើម្បីស្វែងយល់កាន់តែច្បាស់ពីសមត្ថភាពចំណាយ ការសម្រេចចិត្តទិញ និងហេតុផលណាមួយដែលអាចបណ្តាលអោយមានការស្ទាក់ស្ទើរក្នុងការងាកមកប្រើប្រាស់ចង្ក្រានអគ្គិសនី។ នៅខែវិច្ឆិកា ឆ្នាំ២០២៥ គម្រោង AIR-C3 ក៏បានបញ្ចប់វគ្គស្ទង់មតិជាមួយគ្រួសារចំនួន ២,៦២២ នៅទូទាំង ៦៥ ភូមិ។ លទ្ធផលនៃការស្ទង់មិតិ បានបង្ហាញពីការបន្តប្រើប្រាស់ឥន្ធនៈជីវម៉ាសរួមជាមួយឧស្ម័នហ្គាសគឺជាជម្រើសដ៏ពេញនិយម ហើយការទទួលបានអគ្គិសនីប្រើតាមផ្ទះកាន់តែមានភាពទំលំទូលាយ និងមើលឃើញពីឱកាសនៃការគាំទ្រដល់ការប្រើប្រាស់ចង្ក្រានអគ្គិសីផងដែរ។

សរុបមក វាបង្ហាញឱ្យឃើញពីកាលានុវត្តភាព និងឧបសគ្គសំខាន់ៗ ពាក់ព័ន្ធនឹងការទិញចង្ក្រានយកទៅប្រើប្រាស់ លទ្ធភាពអាចទិញបាន និងការបន្តប្រើប្រាស់ចង្ក្រានអគ្គិសនី ហើយយើងក៏បានយករបកគំហើយនោះមកបង្កើតកម្មវិធី **"ចង្ក្រានឆ្លាតវៃ"**។



## អំពី "ចង្ក្រានឆ្លាតវៃ"

**"ចង្ក្រានឆ្លាតវៃ"** គឺជាម៉ាកយីហោកម្មវិធីដែលត្រូវបានបង្កើតឡើងសម្រាប់ផ្សព្វផ្សាយពីចង្ក្រានអគ្គិសនី ក្នុងគោលបំណងដោះស្រាយឧបសគ្គរាំងដល់ការស្វែងរកទិញចង្ក្រានអគ្គិសនី និងជំរុញដល់ការទទួលយកចង្ក្រានអគ្គិសនីសម្រាប់ប្រើប្រាស់ ព្រមទាំងគាំទ្រដល់ការអនុវត្តការចម្អិនអាហារស្អាតនៅក្នុងភូមិផងដែរ។ កម្មវិធីនេះ ផ្សព្វផ្សាយចង្ក្រានអគ្គិសនីនៃក្រុមហ៊ុន ATEC  ម៉ាក eCook v3 ដែលត្រូវបានរចនាឡើងជាពិសេសសម្រាប់បរិបទនៅក្នុងប្រទេសកម្ពុជា ហើយរាល់ការទិញចង្ក្រានអគ្គិសនីនឹងមានបន្ថែមជូនខ្ទះមួយ និងឆ្នាំងអ៊ីណុកមួយផងដែរ ជាពិសេសមានការធានារយៈពេល ២ ឆ្នាំ។

**កម្មវិធីនេះមានសកម្មភាពដូចជា៖** ការចុះតាមសហគមន៍ យុទ្ធនាការផ្លាស់ប្តូឥរិយាបថ ការលក់តាមផ្ទះ និងការគាំទ្រដល់គ្រួសារផ្ទាល់ ដើម្បីលើកទឹកចិត្តដល់ការប្រើប្រាស់ចង្ក្រានអគ្គិសនីក្នុងរយៈពេលយូរ។ សកម្មភាពទាំងនេះកំពុងត្រូវបានអនុវត្ត សិក្សានិងវាយតម្លៃតាមរយៈគម្រោង AIR-C3 ដើម្បីស្វែងយល់ពីការលើកកម្ពស់ក្នុងការទទួលយក និងការបន្តប្រើប្រាស់ចង្ក្រានអគ្គិសនី ខណៈកាត់បន្ថយការពឹងផ្អែកលើការប្រើប្រាស់ឥន្ធនៈជីវម៉ាស។



### ការបង្កើតបរិយាកាសអំណោយផល

ជំនួបជាមួយថ្នាក់ដឹកនាំស្រុក ឃុំ និងភូមិ ដើម្បីសុំការអនុញ្ញាតការគាំទ្រដល់ការរៀបចំផែនការការសម្របសម្រួល និងការអនុវត្តកម្មវិធី "ចង្ក្រានឆ្លាតវៃ" ព្រមទាំងជួយសម្រួលដល់ការចូលរួមរបស់គ្រួសារក្នុងតំបន់អោយបានពេញលេញ។



### សកម្មភាពបង្ហាញក្នុងសហគមន៍

កម្មវិធីសម្ពោធ "ចង្ក្រានឆ្លាតវៃ" ណែនាំអំពីកម្មវិធីលើកទឹកចិត្តឱ្យពិចារណាពីបញ្ហាប្រឈមដែលទាក់ទងនឹងការចម្អិនអាហារដោយឥន្ធនៈជីវម៉ាស និងលើកកម្ពស់ការយល់ដឹងអំពីការចម្អិនអាហារដោយចង្ក្រានអគ្គិសនី។



### ការបង្ហាញសាកល្បងជាក្រុមតូច

ការបង្ហាញសាកល្បងជាក្រុមតូចរបស់ "ចង្ក្រានឆ្លាតវៃ" ផ្តល់ឱកាសឱ្យគ្រួសារបានសិក្សា និងសាកផ្ទាល់អំពីការចម្អិនអាហារដោយចង្ក្រានអគ្គិសនី និងជួបជាមួយអ្នកជិតខាងដែលបានទិញ និងកំពុងប្រើប្រាស់ចង្ក្រានអគ្គិសនី។



### ការគាំទ្រដល់គ្រួសារផ្ទាល់

អ្នកទិញទាំងអស់នឹងទទួលបានការដឹកជញ្ជូនចង្ក្រាន ការណែនាំពីការប្រើប្រាស់លើកដំបូង និងការចាំជួយគាំទ្រក្រោយពីការលក់។ នៅភូមិគោលដៅដែលត្រូវបានជ្រើសរើស ភ្នាក់ងារលក់នឹងមកលក់តាមផ្ទះ ហើយគ្រួសារដែលមានចំណូលទាបនឹងមានឱកាសទទួលបានការឧបត្ថម្ភធនខ្លះៗដែរ។

## សារសំខាន់ៗរបស់ "ចង្ក្រានឆ្លាតវៃ"

"ចង្ក្រានឆ្លាតវៃ" អនុលោមទៅតាមពាក្យស្លោកមួយគឺ **"ផ្ទះបាយស្អាត គ្រួសាររីករាយ"**។ សារសំខាន់ៗទាំង ៧ ខាងក្រោមនេះ ត្រូវបានប្រើប្រាស់គ្រប់សកម្មភាពនៃកម្មវិធី និងបញ្ចូលទៅក្នុងឯកសារផ្សព្វផ្សាយទាំងអស់ ដើម្បីគាំទ្រដល់ការសម្រេចចិត្ត និងជំរុញទឹកចិត្តផ្លាស់ប្តូរពីចង្ក្រានប្រើអុស ឬធ្យូង អោយងាកមកប្រើប្រាស់ចង្ក្រានអគ្គិសនីវិញ។

**1. ការចម្អិនអាហារកាន់តែស្អាត និងទំនើបទាន់សម័យ៖** ចង្ក្រានអគ្គិសនីជាបច្ចេកវិទ្យាថ្មី និងឆ្លាតវៃ ជាជម្រើសទំនើបជំនួសឱ្យអុស ធ្យូង និងហ្គាសសម្រាប់គ្រួសារដែលមានអគ្គិសនីប្រើ។

- នាំមកជូននូវបច្ចេកវិទ្យាចម្អិនអាហារបែបទំនើប និងឆ្លាតវៃ។
- រចនាឡើងជាជម្រើសទំនើបជំនួសឱ្យការចម្អិនអាហារដោយធ្យូង អុស និងឧស្ម័ន LPG នៅកម្ពុជា។
- តាមរយៈកម្មវិធីនេះ គ្រួសារនៅក្នុងភូមិដែលចូលរួម មានឱកាសសិក្សា និងទទួលបានបច្ចេកវិទ្យាចម្អិនអាហារថ្មី ទំនើប។

**2. ចម្អិនកាន់តែលឿន និងងាយស្រួល** ចង្ក្រានអគ្គិសនីមានជម្រើសធ្វើអោយក្តៅលឿន និងងាយស្រួលប្រើ ជួយកាត់បន្ថយពេលវេលារៀបចំ និងប្រមូលអុស ឬបញ្ចូលឧស្ម័ន LPG ។

- មិនចាំបាច់រៀបចំ ប្រមូលអុស ឬបញ្ចូលឧស្ម័ន LPG ដែលធ្វើឱ្យដំណើរការរៀបចំអាហារប្រចាំថ្ងៃកាន់តែងាយស្រួល។
- កម្តៅឡើងលឿន ដែលជួយកាត់បន្ថយពេលវេលាក្នុងការរៀបចំអាហារបើប្រៀបធៀបនឹងចង្ក្រានឥន្ធនៈជីវម៉ាស និងចង្ក្រានហ្គាស។
- មុខងារកំណត់កម្រិតកម្តៅអនុញ្ញាតឱ្យអ្នកចម្អិនកែសម្រួលកម្តៅយ៉ាងលឿន និងច្បាស់លាស់ ដែលជួយធានាថាអាហារឆ្អិនសព្វល្អ និងមិនខ្លោច។
- ការណែនាំ និងបង្ហាញសាកល្បង ជួយឱ្យគ្រួសារស្វែងយល់អំពីរបៀបប្រើប្រាស់ចង្ក្រានដោយទំនុកចិត្ត។

**3. ចម្អិនអាហារដោយសន្សំសំចៃ៖** ចង្ក្រានអាំងឌុចស្យុងប្រើប្រាស់អគ្គិសនីប្រកបដោយប្រសិទ្ធភាព និងជួយកាត់បន្ថយការចំណាយ

- ប្រើភ្លើងដោយសន្សំសំចៃខ្ពស់ ព្រោះកម្តៅត្រូវបានចម្លងទៅឆ្នាំង ឬខ្ទះផ្ទាល់ មិនខ្ជះខ្ជាយ
- មិនចាំបាច់ទិញធ្យូង អុស ឬហ្គាស ម្តងហើយម្តងទៀតជារៀងរាល់ខែ
- គ្រួសារស្ថិតក្នុងភូមិគោលដៅដែលបានចូលរួមកម្មវិធី នឹងទទួលបានតម្លៃពិសេសក្រោមការគាំទ្ររបស់គម្រោង

**4. សុវត្ថិភាពខ្ពស់សម្រាប់គ្រួសារ៖** ចង្ក្រានអាំងឌុចស្យុងជួយកាត់បន្ថយហានិភ័យ

- គ្មានអណ្តាតភ្លើង កាត់បន្ថយហានិភ័យរលាក និងភ្លើងឆាបឆេះ
- ផ្ទៃចង្ក្រានត្រជាក់ជាងចង្ក្រានធម្មតា
- មានមុខងារសុវត្ថិភាពដូចជា៖ មុខងារចាក់សោការពារពីកុមារ មុខងារកំណត់រយៈពេលចម្អិន និងមុខងារឆ្លាតវៃដែលអាចស្គាល់ឆ្នាំងកំពុងចម្អិន

**5. ផ្ទះបាយស្អាត គ្មានផ្សែង មានផាសុខភាព៖** ការចម្អិនអាហារដោយអគ្គិសនី ជំនួសឱ្យធ្យូង ឬអុស និងជួយឱ្យផ្ទះបាយស្អាត និងគ្មានផ្សែង

- គ្មានផ្សែងពីការដុតឥន្ធនៈដូចជាអុស ឬធ្យូង ធ្វើឱ្យបរិយាកាសក្នុងផ្ទះស្អាត
- កម្តៅក្នុងផ្ទះបាយតិចតួច ធ្វើអោយស្រួលខ្លួនសម្រាប់អ្នកចម្អិន
- ផ្ទះបាយ និងឆ្នាំងស្អាត ជានិច្ចដោយមិនមានស្នាមប្រឡាក់ ឬផេះខ្មៅជាប់
- ផ្ទៃកញ្ចក់រលោង អាចជូតសម្អាតបានយ៉ាងងាយ

**6. ប្រើដោយទំនុកចិត្ត និងមានការជួយគាំទ្រ៖** អាចឱ្យគ្រួសារចម្អិនអាហារដោយទំនុកចិត្ត និងទទួលបានជំនួយប្រសិនបើត្រូវការ។

- មានការធានា ២ ឆ្នាំ បើខូច ផ្តល់ការជួសជុល
- មានសេវាដឹកជញ្ជូន និងតម្លើងជូនដល់ផ្ទះ
- មានការគាំទ្រក្រោយការលក់ ប្រសិនបើត្រូវការជំនួយ
- មានឱកាស ដើម្បីសិក្សាពីអ្នកប្រើប្រាស់ចង្ក្រានអគ្គិសនីដទៃទៀត

ផលិតដោយក្រុមហ៊ុន ATEC ដែលជាក្រុមហ៊ុនផលិតចង្ក្រានអន្តរជាតិ កម្មវិធីនេះត្រូវបានអនុវត្តដោយ iDE កម្ពុជា ដែលជាអង្គការដែលមានបទពិសោធន៍យ៉ាងទូលំទូលាយក្នុងការធ្វើការជាមួយសហគមន៍នៅកម្ពុជា។

**7. ចម្អិនម្ហូបតាមចំណង់ចំណូលចិត្តគ្រួសារអ្នក៖** ដើរយ៉ាងរលូនក្នុងផ្ទះជាច្រើនដែលមានអគ្គិសនីប្រើប្រាស់

- ចម្អិនម្ហូបខ្មែរបានគ្រប់មុខ រស់ជាតិនៅដដែល
- មានមុខចង្ក្រានពីរ អាចចម្អិនម្ហូបច្រើនមុខក្នុងពេលតែមួយ
- ថែមជូនខ្ទះមួយ និងឆ្នាំងអ៊ីណុកដែលត្រូវគ្នាជាមួយចង្ក្រានអគ្គិសនី
- ណែនាំវិធីសាមញ្ញ ដើម្បីពិនិត្យមើលថាតើប្រដាប់ប្រដាចម្អិនរបស់អ្នកត្រូវគ្នាជាមួយចង្ក្រានដែរឬទេ





## សារសំខាន់ៗរបស់ "ចង្ក្រានឆ្លាតវៃ"

AIR-C3 ប្រើប្រាស់វិធីសាស្ត្រជាច្រើន ដើម្បីស្វែងយល់អំពីរបៀបដែលគ្រួសារនីមួយៗទិញចង្ក្រាន យកទៅប្រើប្រាស់ និងការបន្តប្រើប្រាស់ចង្ក្រាន ព្រមទាំងទម្លាប់នៃការចម្អិនអាហារដែលអាចមានការផ្លាស់ប្តូរទៅតាមពេលវេលា។

ជារួមសកម្មភាពទាំងនេះ នឹងជួយវាស់វែងពីផលជះនៃកម្មវិធី «ចង្ក្រានឆ្លាតវៃ»។

- **ការស្ទង់មតិគ្រួសារ៖** សួរសំណួរអំពីរបៀបរបបដែលគ្រួសារនីមួយៗចម្អិនជាប្រចាំដោយប្រើចង្ក្រានណាខ្លះ និងបទពិសោធន៍ថ្មីក្នុងការប្រើចង្ក្រានអគ្គិសនី។
- **ការសម្ភាសន៍៖** ការសម្ភាសន៍ជាមួយសមាជិកសហគមន៍ អ្នកអនុវត្តកម្មវិធី និងភាគីពាក់ព័ន្ធផ្សេងទៀត នឹងផ្តល់នូវការយល់ដឹងស៊ីជម្រៅ អំពីបទពិសោធន៍នានាពាក់ព័ន្ធនឹងការចម្អិនអាហារដោយប្រើចង្ក្រានអគ្គិសនី និងការអនុវត្តរួមនៃកម្មវិធីនេះ។
- **តាមដានការប្រើប្រាស់ចង្ក្រាន៖** ការភ្ជាប់ជាមួយឧបករណ៍តាមដានទៅនឹងចង្ក្រានដោយផ្ទាល់ ដើម្បីផ្តល់ព័ត៌មានអំពីកម្រិតនៃការប្រើប្រាស់បច្ចេកវិទ្យាចម្អិនអាហារខុសៗគ្នា និងការប្រែប្រួលនៃទម្លាប់ចម្អិនអាហារទៅតាមពេលវេលា។
- **ការវាស់គុណភាពខ្យល់៖** ឧបករណ៍តាមដានចល័ត (ដូចរូបខាងស្តាំ) ដែលវាមានសមត្ថភាពអាចជួយឱ្យដឹងពីការផ្លាស់ប្តូរគុណភាពខ្យល់ក្នុងបរិយាកាស ប្រៀបធៀបមុនពេលប្រើ និងក្រោយពេលប្រើចង្ក្រានអគ្គិសនី។

## កាលវិភាគកម្មវិធី

| | | | |
|---|---|---|---|
| **ការអភិវឌ្ឍ និង ការអនុវត្តកម្មវិធី** | **2025-2026**<br>សិក្សាអំពីរបៀបរបបចម្អិនអាហារតាមគ្រួសារ និងការរៀបចំកម្មវិធី | **ចុងឆ្នាំ 2025**<br>ការស្ទង់មតិគ្រួសារមុនពេលអនុវត្តកម្មវិធី | **2026-2027**<br>ការអនុវត្តកម្មវិធី "ចង្ក្រានឆ្លាតវៃ" |
| **ការតាមដាន ការវាយតម្លៃ និងការសិក្សា** | **2026-2028**<br>តាមដានសកម្មភាព និងការត្រួតពិនិត្យបន្ត | **Late-2028**<br>ការស្ទង់មតិគ្រួសារក្រោយការអនុវត្តកម្មវិធី | **2029**<br>ការចែករំលែកលទ្ធផលនៃការសិក្សា និងមេរៀនបទពិសោធន៍ |


### សម្រាប់ព័ត៌មានបន្ថែម

**ថ្នាក់ដឹកនាំគម្រោងសិក្សាស្រាវជ្រាវ**

បណ្ឌិត. Matthew Freeman, ប្រធានផ្នែកត្រួតពិនិត្យនៃសាកលវិទ្យាល័យ Emory
*matthew.freeman@emory.edu*

បណ្ឌិត. Ajay Pillarisetti, ប្រធានផ្នែកត្រួតពិនិត្យនៃសាកលវិទ្យាល័យ California, Berkeley
*ajaypillarisetti@berkeley.edu*

លោក Jedidiah Snyder, អ្នកសម្របសម្រួលគម្រោងនៃសាកលវិទ្យាល័យ Emory
*jedidiah.snyder@emory.edu*

**iDE Cambodia**
ប្រអប់សំបុត្រលេខ ១៥៧៧
ផ្ទះលេខ ៩៧A ផ្លូវ ១៩BT (តាផុន) សង្កាត់បឹងទំពុន ខណ្ឌមានជ័យ
រាជធានីភ្នំពេញ
ទូរស័ព្ទ៖ +855 923 540 or +855 923 541
អ៊ីមែល៖ Cambodia@ideglobal.org


**ស្វែងយល់បន្ថែម**

- www.airc3.org
- www.freemanresearchgroup.org/airc3
- ClinicalTrials.gov: NCT06942715

ចង្ក្រានឆ្លាតវៃ


*ឧបត្ថម្ភថវិកាដោយ វិទ្យាស្ថានជាតិវិទ្យាសាស្ត្រសុខាភិបាលបរិស្ថាន (NIEHS) លេខកូដជំនួយ (Grant) R01ES035395*